KIDS GOD WORSHIP

www.kidworship.kr



23Page

# ទូកណូអេ

## - 4th Story -

**Nar** ច្រើនឆ្នាំកន្លងផុតទៅ ក្រៅពីអាដាមនិងអេវ៉ា
ក៏មានមនុស្សបានកើតមកជាច្រើនឡើងនៅលើផែនដី។
ប៉ុន្តែ ព្រះជាម្ចាស់បានមើលឃើញថា
មនុស្សធ្វើអាក្រក់កាន់តែច្រើនឡើងនៅផែនដី
ហេតុនេះបានជាព្រះជាម្ចាស់មានចិត្តឈឺចាប់យ៉ាងខ្លាំង។

**God** ផែនដីនេះ មានពេញដោយអំពើអាក្រក់ជាច្រើន។
យើងសោកស្ដាយណាស់ ដែលបានបង្កើតមនុស្សមក។
យើងនឹងដកមនុស្សចេញពីផែនដីនេះវិញ។

**Nar** ប៉ុន្តែ មានបុរសម្នាក់ជាមនុស្សល្អនៅលើផែនដី។
គាត់ឈ្មោះថា «ណូអេ»។
ណូអេបានស្រលាញ់ដល់អ្នកជិតខាងនិងបានស្រលាញ់ដល់ព្រះជាម្ចាស់។
គាត់តែងតែដើរតាមព្រះជាម្ចាស់ជានិច្ច
ហេតុនេះទើបព្រះជាម្ចាស់បានជ្រើសរើសគាត់។

**God** ណូអេអើយ! យើងនឹងនាំយកទឹកជំនន់ដ៏ធំមួយមក
ដើម្បីបំផ្លាញគ្រប់ជីវិតនៅលើផែនដី។
ប៉ុន្តែយើងនឹងសន្យាជាមួយឯងថា
យើងនឹងជួយសង្គ្រោះឯងហើយនិងគ្រួសាររបស់ឯង
ព្រមទាំងសត្វមានជីវិតញីឈ្មោលមួយគូរៗគ្រប់ប្រភេទ។
ឯងត្រូវតែសង់ទូកធំមួយនៅលើកំពូលភ្នំ។

**Nar** តាមការបង្គាប់របស់ព្រះជាម្ចាស់
ណូអេក៏បានចាប់ផ្តើមសង់ទូកធំមួយពីឈើម៉ៃសាក។
ពេលនោះ មានមនុស្សជាច្រើន បានសើចចំអកដល់គាត់ ។

**Man** ហាហា ណូអេឆ្កួតហើយ!
គាត់កំពុងសង់ទូកដ៏ធំមួយនៅលើកំពូលភ្នំ
ដែលជាកន្លែងគ្មានទឹកទាល់តែសោះ!

**Woman** ណូអេពិតជាឡប់មែនហើយ!
គាត់ប្រាប់ថា ភ្លៀងនឹងធ្លាក់ចុះមកក្លាយជាទឹកជំនន់
ខណៈពេលដែល មេឃស្រឡះល្អសោះហ្នឹង!
ប៉ុន្តែណូអេប្រាប់ថា នឹងមានភ្លៀងក្លាយជាទឹកជំនន់ទៅវិញ?
លើកនេះ គាត់ពិតជាឆ្កួតច្បាស់ណាស់!



24Page

**Nar** ណូអេបានសង់ទូកធំមួយតាមការប្រាប់របស់ព្រះជាម្ចាស់។
ដូច្នេះ ពេលនោះ ទូកធំណូអេអាចដាក់សត្វញីឈ្មោល១គូៗ
ទៅតាមប្រភេទចូលទៅក្នុងទូកបាន។

**God** ប្រាំពីរថ្ងៃក្រោយ យើងនឹងនាំយកទឹកភ្លៀងពីលើមេឃមកផែនដី
ក្នុងរយៈពេល៤០ថ្ងៃនិង៤០យប់។
នៅថ្ងៃនោះ សត្វមានជីវិត១គូៗ បានចូលទៅក្នុងទូកណូអេ។

**Nar** មានដូចជា៖ ដំរី គោ សត្វកវែង ទោះទាំងបក្សីហើរនៅលើមេឃ
ក៏បានចូលទៅក្នុងទូកគាត់ដែរ។
ទូកធំណូអេ មានពេញដោយសត្វជាច្រើនប្រភេទ។
ចំណែកមនុស្សវិញ មានត្រឹមតែណូអេនិងប្រពន្ធ
ព្រមទាំងកូនប្រុសទាំង៣ដែលមានឈ្មោះថា
សិម ហាំ និងយ៉ាផែតព្រមទាំងប្រពន្ធរបស់ពួកគេ។
មនុស្សគឺមានតែ៨នាក់ប៉ុណ្ណោះ ដែលបានចូលទៅក្នុងទូកនោះ។



25Page

**Nar** ក្រោយពេលទ្វារទូកបានបិតជិត ភ្លៀងក៏បានធ្លាក់ពីលើមេឃមកយ៉ាងខ្លាំង។
ភ្លៀងបានបន្តធ្លាក់មកទាំងថ្ងៃទាំងយប់។
ឯទឹកក៏បានកើនឡើងរហូតដល់លិចផែនដីទាំងមូល។
គ្មានអ្វីដែលរស់នៅលើផែនដីទៀតទេ
គឺមានតែគ្រួសារណូអេនិងសត្វដែលនៅក្នុងទូកប៉ុណ្ណោះ។

**Nar** ទីបំផុត ភ្លៀងក៏បានឈប់នៅថ្ងៃទី៤០។
ផែនដីទាំងមូល ពោរពេញដោយទឹក។ គ្មានអ្វីនៅសល់ទេ។
ប៉ុន្តែគ្រួសារណូអេ ព្រមទាំងសត្វនៅក្នុងទូកធំបានរស់ដោយសុវត្ថិភាព។
ថ្ងៃមួយ ណូអេបានព្រលែងសត្វព្រាបមួយក្បាលឲ្យចេញពីទូកហើរទៅ។
ប៉ុន្តែសត្វព្រាបនោះ មិនអាចរកកន្លែងទុំបាន
ដូច្នេះក៏បានហើរត្រលប់មកឯទូកវិញ។
ប្រាំពីរថ្ងៃក្រោយមក
ណូអេបានព្រលែងសត្វព្រាបមួយទៀតឲ្យចេញពីទូកហើរទៅ។
ពេលនោះ សត្វព្រាបក៏បានត្រលប់មកទូកវិញជាមួយស្លឹកអូលីវ
នៅក្នុងចំពុះរបស់វា។
បន្ទាប់មកទៀត ណូអេបានដឹងថា ទឹកបានស្រកពីផែនដីបន្តិចហើយ។



26Page

**Nar** ៣៧០ថ្ងៃ បានកន្លងផុតទៅ មុនពេលទឹកស្រកស្ងួតពីផែនដីអស់។
ពេលនោះ ព្រះជាម្ចាស់បានប្រាប់ណូអេថា

**God** ឯងនិងគ្រួសារឯង អាចចេញពីទូកបានហើយ។



27Page

**Nar** ណូអេនិងគ្រួសារ បានចេញពីទូកមក។
សត្វទាំងអស់ ក៏បានចេញពីទូកមកដែរ។
បន្ទាប់មក គាត់បានសង់កន្លែងមួយ
ដើម្បីថ្វាយបង្គំព្រះជាម្ចាស់និងបានយកដង្វាយ
ទុកជាការអរគុណដល់ព្រះជាម្ចាស់ផងដែរ។

**God** យើងនឹងមិនដាក់បណ្ដាសារដល់ផែនដីដូចនេះទៀតទេ!

**Nar** ព្រះជាម្ចាស់បានដាក់ឥន្ទធនូនៅលើពពក។
ឥន្ទធនូនេះ គឺជាសញ្ញាសំគាល់នៃការសន្យារបស់ព្រះជាម្ចាស់ថា
«ព្រះអង្គនឹងមិនបំផ្លាញមនុស្សនិងសត្វដោយទឹកជំនន់ទៀតទេ»។